# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




**Asian International Justice Initiative (AIJI), a project of East-West Center and the WSD Handa Center for Human Rights and International Justice at Stanford University (previously known as the UC Berkeley War Crimes Studies Center)**

# របាយការណ៍សង្ខេប លេខ ៣

អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក បានចាប់ផ្តើមបើកសវនាការសាជាថ្មីលើសំណុំរឿង០០២ វគ្គទី២ នៅក្នុងខែនេះ ដោយមានគោលបំណងបង្ខំឲ្យក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទទាំងពីររូប គឺលោក **នួន ជា** និងលោក **ខៀវ សំផន** ចូលរួមក្នុងកិច្ចដំណើរការនីតិវិធីសវនាការ បន្ទាប់ពីមានការផ្អាកសវនាការមួយខែ ចាប់តាំងពីថ្ងៃបើកកិច្ចពិភាក្សាដេញដោលនៅថ្ងៃទី១៧ ខែតុលា មក។ នៅមុនពេលកំណត់កាលវិភាគឈប់សម្រាករបស់តុលាការក្នុងឱកាសពិធីបុណ្យអុំទូករបស់ប្រទេសកម្ពុជា អង្គជំនុំជម្រះ បានចេញដីកាកំណត់កាលវិភាគថ្មីមួយ ដែលបានកាត់បន្ថយចំនួនថ្ងៃសវនាការដែលនៅសល់មុនដំណាច់ឆ្នាំ២០១៤ ពី១៥ថ្ងៃ មក ១០ថ្ងៃ វិញ។ ដោយរក្សាទុកកាលវិភាគថ្មីនេះ និងឆ្លើយតបទៅនឹងការធ្វើយុត្តិកម្មលើការបន្តអវត្តមានរបស់ក្រុមមេធាវីការពារក្តីឲ្យលោក **នួន ជា** ក្នុងកិច្ចដំណើរការនីតិវិធីសវនាការ ក្រុមប្រឹក្សាជំនុំជម្រះពិសេស ដែលចាត់តាំងដោយគណៈកម្មាធិការរដ្ឋបាលតុលាការរបស់ អ.វ.ត.ក ក៏បានចេញនូវសេចក្តីសម្រេចរបស់ខ្លួនលើសំណើប្តឹងជំទាស់ចិត្តចៅក្រមរបស់ក្រុមមេធាវីការពារក្តី។ ដូច្នេះហើយ ជនជាប់ចោទលោក **នួន ជា** និងមេធាវីការពារក្តីរបស់គាត់ បានចូលរួមក្នុងសវនាការនៅពីថ្ងៃទី១៧ និងទី២៤ ខែវិច្ឆិកានេះ ក៏ប៉ុន្តែ ក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទលោក **ខៀវ សំផន** បានបន្តធ្វើពហិការ ដែលបានធ្វើឲ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាកែប្រែផែនការរបស់ខ្លួនសម្រាប់សវនាការដែលនៅសល់ក្នុងឆ្នាំនេះ។

តាមរយៈកិច្ចពិភាក្សាផ្លាស់ប្តូរគ្នាជាមួយនឹងជនជាប់ចោទលោក **ខៀវ សំផន** ក្នុងសាលសវនាការនៅថ្ងៃទី១៧ ខែវិច្ឆិកា និងក្នុងសេចក្តីសម្រេចចុះថ្ងៃទី២១ ខែវិច្ឆិកា អង្គជំនុំជម្រះបានប្រកាសថា តុលាការបានកំណត់មុខងាររបស់មេធាវីបច្ចុប្បន្នរបស់លោក **ខៀវ សំផន** ជា "មេធាវីដែលចាត់តាំងដោយតុលាការ" ដោយមានគោលបំណងបង្ការមេធាវីមិនឲ្យបន្តគោរពតាមការណែនាំរបស់កូនក្តីរបស់ពួកគេក្នុងការធ្វើពហិការ។ ដោយធ្វើដូច្នេះ តុលាការបានយល់ឃើញថា ផលប្រយោជន៍យុត្តិធម៌ និងការជំនុំជម្រះក្តីប្រកបដោយភាពឆាប់រហ័ស មានសារសំខាន់ជាងសិទ្ធិជាក់លាក់របស់ជនជាប់ចោទក្នុងការមានមេធាវីតាមការជ្រើសរើសរបស់គាត់។ ជាកិច្ចឆ្លើយតបមេធាវីការពារក្តីឲ្យលោក **ខៀវ សំផន** បានចេញនូវសេចក្តីប្រកាសព័ត៌មានមួយភ្លាមៗ នៅមុនពេលចាប់ផ្តើមសវនាការនៅថ្ងៃទី២៤ ខែវិច្ឆិកានេះ ដោយពួកគេបានធ្វើការបដិសេធ ដើម្បីឲ្យទទួលយកនូវការទាមទាររបស់ពួកគេ ដែលសវនាការលើសំណុំរឿង០០២ វគ្គទី២ ត្រូវចាប់ផ្តើមនៅក្រោយថ្ងៃផុតកំណត់នៃការប្តឹងសាទុក្ខលើសំណុំរឿង០០២ វគ្គទី១ គឺនៅថ្ងៃបន្ទាប់ពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ នេះសិន។ ដោយប្រឈមមុខនឹងការគ្មានជម្រើសជាបន្តបន្ទាប់ និងកាលបរិច្ឆេទថ្ងៃធ្វើសវនាការក៏មានចំនួនតិចតួចក្នុងប្រតិទិនប្រចាំឆ្នាំរបស់តុលាការ អង្គជំនុំជម្រះសាលាដំបូង បានបន្ធូរឥរិយាបថ និងបានប្រកាសផ្អាកសវនាការរហូតដល់ថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥ ខាងមុខនេះ។

សម្រាប់មិត្តអ្នកអានក្នុងស្រុក សូមមេត្តាកត់សម្គាល់ផងដែរថា អង្គការគម្រោងផ្តួចផ្តើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី (AIJI) បានធ្វើការចុះផ្សាយនូវរបាយការណ៍សង្ខេបជាខេមរភាសា លេខ៣ នេះ។ AIJI នឹងបន្តធ្វើការចុះផ្សាយជាទៀងទាត់ នូវរបាយការណ៍សង្ខេបជាខេមរភាសា ដោយនឹងចេញផ្សាយនូវការបកប្រែរបាយការណ៍ទាំងមូលនៅពេលខាងមុខនេះ។

EAST-WEST CENTER

AIJI TRIAL MONITORING

WSDHANDACENTER
FOR HUMAN RIGHTS & INTERNATIONAL JUSTICE
Stanford University

---

* របាយការណ៍នេះ ត្រូវបានសរសេរដោយ វ៉ាន់ណេសសា ហាហ្គើ (Vanessa Hager), ដានៀល ម៉ាតថេស៍ (Daniel Mattes), តាយ លីណា, ភីណឺឡូភី វ៉ាន់ ធូល (Penelope Van Tuyl), និង វង្ស ឧត្តម ដែលជាផ្នែកមួយនៃកម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម និងការផ្សព្វផ្សាយតាមសហគមន៍របស់អង្គការគម្រោងផ្តួចផ្តើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី (AIJI)។ អង្គការ AIJI គឺជាគម្រោងកិច្ចសហប្រតិបត្តិការរវាង មជ្ឈមណ្ឌលបស្ចិម-បូព៌ា (East-West Center) នៅអូណូឡូឡូ (Honolulu)និងមជ្ឈមណ្ឌលដាប់ប៊ែលយូ.អេស.ឌី ហាន់ដា សម្រាប់សិទ្ធិមនុស្ស និងយុត្តិធម៌ អន្តរជាតិ (WSD Handa Center) ដែលកាលពីមុន ត្រូវបានគេស្គាល់ថាជា មជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាម ប៊ែកឃ្លី (Berkeley War Crime Study Center)។ ចាប់តាំងពីឆ្នាំ២០០៣មក មជ្ឈមណ្ឌលទាំងពីរនេះ បានកំពុងធ្វើកិច្ចសហប្រតិបត្តិការគ្នាលើគម្រោងជាច្រើន ដែលពាក់ព័ន្ធនឹងការបង្កើតការផ្តួចផ្តើមយុត្តិធម៌ និងកម្មវិធីកសាងសមត្ថភាពនានា ក្នុងវិស័យសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីអាគ្នេយ៍នេះ។